ស

# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

កម្មវិធីរបស់ The Asian International Justice Initiative

ឆ្នាំទី១ លេខ ៩ សប្តាហ៍ទី ៩ (២២ ‑ ២៥ មិថុនា ឆ្នាំ២០០៩)

## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្កិចអាវ ហៅ ឌុច"



*រូបភាព: ឌុចក្នុងបន្ទប់សវនាការ*

## ១. សេចក្តីសង្ខេប

*"ខ្ញុំមានអារម្មណ៍ក្តុកក្តួលនៅពេលទៅជើងឯក(...)ខ្ញុំនិយាយមិនចេញ"*[១]

*"ខ្ញុំសុខចិត្តទទួលខុសត្រូវចំពោះព្រលឹងអ្នកស្លាប់"*[២]

សវនាការរយៈពេលពីរថ្ងៃដំបូងនាសប្តាហ៍នេះ ភាគីសួរដេញដោលជនជាប់ចោទលើអង្គហេតុ *"តួនាទីមន្ទីរ ស-២១"* និង *"ការសម្លាប់នៅមន្ទីរ ស-២១ បរិវេណជុំវិញមន្ទីរ ស-២១ និងជើងឯក"* ។ ថ្ងៃពុធ និងថ្ងៃប្រហស្បតិ៍ ការសួរដេញដោលលើអង្គហេតុ *"ការបង្កើត និងមុខងារមន្ទីរអប់រំកែប្រែព្រៃស ( មន្ទីរ ស-២៤)"* ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្មរបស់ជនជាប់ចោទ ស្តីពីប្រតិបត្តិការមន្ទីរ ស‑២១ និងជើងឯក

នៅសប្តាហ៍នេះ សហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹង និងមេធាវីការពារក្តីបានសួរដេញដោលជនជាប់ចោទលើអង្គហេតុប្រតិបត្តិការមន្ទីរ ស-២១ និងជើងឯក ។

***ការងារប្រចាំថ្ងៃ :*** **ឌុច** ធ្វើការ ១២ម៉ោង ក្នុងមួយថ្ងៃ ការងាររបស់គាត់មានបីធំៗ គឺការងារឃោធា ការធ្វើចំណារលើចម្លើយ

[១] ឌុចបានរៀបរាប់នៅថ្ងៃទី២៣ ខែមិថុនា ២០០៩ ពេលគាត់បានទៅជើងឯក កាលពីខែកុម្ភៈ ឆ្នាំ២០០៨

[២] ឌុច បានរៀបរាប់នៅថ្ងៃ២៥ ខែមិថុនា ២០០៩ អំពីបញ្ជីឈ្មោះកុមារចំនួន១៦០នាក់ដែលយកពីព្រៃស ទៅកំទេចនៅជើងឯក ។

សារភាព និងការបណ្តុះបណ្តាល ។ គាត់ចំណាយពេលស្ទើរតែទាំងអស់ចារលើចម្លើយសារភាព ។ **ឌុច** បានឱ្យដឹងថា គាត់ទទួលទានអាហារថ្ងៃត្រង់ និងល្ងាច នៅផ្ទះបាយរួម ហើយជានិច្ចកាលអង្គុយតុរួមជាមួយ **ម៉ម ណៃ** និង **ប៊ុន** ពេលខ្លះ **ហូ** ចូលរួមផងដែរ ។ បុគ្គលិកមន្ទីរ ស-២១ ក៏បរិភោគនៅទីនោះ លើកលែងតែអ្នកយាម ។ **ឌុច** អះអាងថា គាត់មិនសូវចំណាយពេលជជែកលេងជាមួយពួកគេទេ ប៉ុន្តែនៅតែទទួលព័ត៌មានកើតឡើងជាប្រចាំ។ បុគ្គលិកបរិភោគល្អជាងអាហារអ្នកទោស ។

***ការសួរចម្លើយ :*** **ឌុច** អះអាងថា តែងតែបង្រៀនអ្នកសួរចម្លើយអំពីការយកចម្លើយសារភាពអ្នកទោស ប៉ុន្តែមិនបានចូលរួមសួរចម្លើយដោយផ្ទាល់ទេ ។ គាត់បានសារភាពថា គាត់បានទះកំភ្លៀងអ្នកទោសម្នាក់ បន្ទាប់ពីទទួលចម្លើយសារភាព ការធ្វើបែបនេះកុំឱ្យ **ណាត** ធ្វើទារុណកម្មលើអ្នកទោសនោះដោយផ្ទាល់ដៃ ។

***មន្ទីរម-២១ :*** ពាក្យ *ម-២១* គឺដើម្បីជំនួសមន្ទីរ ស-២១ **ណាត** ប្រើឈ្មោះនេះដោយថ្នាក់លើមិនបានដឹងឡើយ គោលបំណងប្រើសម្រាប់ចាប់ខ្លួនមនុស្សពី ស្វាង និង កៀនស្វាយ ។ ជាងនេះទៀត ពាក្យ ម-០៣ ត្រូវបានប្រើកំទេចអ្នកនៅតំបន់មជ្ឈិម ។

តាមសក្ខីកម្ម **ឌុច** មានតែ **ណាត** ទេ ដែលមានអំណាចនៅមន្ទីរ ម-២១ ចំណែកគាត់គ្រាន់តែជាលេខា **ណាត** ប៉ុណ្ណោះ ដើម្បីបញ្ជាក់សក្ខីកម្មនេះ **ឌុច** បានបង្ហាញឯកសារមួយចំនួនដែលថា **ណាត** ជាអ្នកគ្រប់គ្រងមន្ទីរ ម-២១ ។

***វិប្បដិសារីរបស់ជនជាប់ចោទ :*** **ឌុច** បានសម្តែងការសោកស្តាយចំពោះទង្វើខ្លួន និងបានសុំទោសជនរងគ្រោះនៅមន្ទីរ ស-២១ ។ មេធាវីការពារក្តីបានស្នើបង្ហាញខ្សែវីដេអូខ្លីបង្ហាញពីសកម្មភាព **ឌុច** ទៅទស្សនៈកិច្ចនៅមន្ទីរ ស-២១ និងជើងឯក កាលពីខែកុម្ភៈ ឆ្នាំ២០០៨ ។ ខ្សែវីដេអូនេះបង្ហាញពីការរំជួលចិត្តយ៉ាងខ្លាំង ពេលគាត់អានអត្ថបទសុំទោសចំពោះជនរងគ្រោះនៅមន្ទីរ ស-២១ ។ **ឌុច** បានរៀបរាប់ថា គាត់តែងតែបួងសួង និងឧទ្ទិសដ្ឋានដល់ជនរងគ្រោះស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមុនការចាប់ខ្លួន ។

## ខ. សេចក្តីសង្ខេបសក្ខីកម្មរបស់ជនជាប់ចោទ ស្តីពីដំណើរការនៅមន្ទីរអប់រំកែប្រែព្រៃស (ស-២៤)

***ដំណើរការមន្ទីរអប់រំកែប្រែព្រៃស :*** មណ្ឌលអប់រំកែប្រែព្រៃសត្រូវបាន **ណាត** ដាក់ឈ្មោះថាមន្ទីរ ស-២៤ ដែលជាផ្នែកមួយរបស់មន្ទីរ ស-២១។ មន្ទីរនេះត្រូវបានបង្កើតឡើងបន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដើម្បី *អប់រំកែប្រែ* អ្នកដែលថ្នាក់លើសង្ស័យ ។ គោលបំណងរបស់មន្ទីរនេះ គឺលត់ដំអ្នកទោសដែលមិនគោរពវិន័យ ឱ្យធ្វើការងារជាទម្ងន់ និងចេះគោរពថ្នាក់លើ ។

***អ្នកជាប់ឃុំឃាំង :*** អ្នកជាប់ឃុំនៅមន្ទីរ ស-២៤ គឺជាអ្នកដែលមិនទាន់កំណត់ថា មិត្ត ឬសត្រូវ ដែលនេះជានយោបាយថ្នាក់លើ។ អ្នកទោសត្រូវឃុំឃាំងនៅមន្ទីរនោះ ដែលជា *"គុកឥតជញ្ជាំង"* ព្រោះគ្មាននរណាហ៊ានរត់គេចខ្លួនទេ ។

អ្នកជាប់ឃុំនៅព្រៃសត្រូវបានចាត់ជាបីក្រុម ផ្អែកតាម *"ចរិកលក្ខណៈធម្មជាតិ និងគោលជំហររបស់ពួកគេ"* ។ ក្រុមទី១ ហៅថាក្រុមមានកំហុសស្រាល ក្រុមទី២ ជាក្រុមមានកំហុសមធ្យម និងក្រុមទី៣ ក្រុមអាចបង្កគ្រោះថ្នាក់ដល់បក្ស ។ ចំណាត់ថ្នាក់នេះអាចត្រូវផ្លាស់ប្តូរបាន ដូចជា ក្រុមទី១ ឬទី២ អាចក្លាយជាក្រុមទី៣ ប៉ុន្តែក្រុមទី៣ មិនអាចប្តូរជាក្រុមទី១ ឬទី២ ទេ ។ ជាគោលការណ៍មនុស្សជាប់នៅមន្ទីរអប់រំកែប្រែព្រៃសនឹងឈានដល់ការកំទេច ។

***ការអប់រំកែប្រែ :*** អ្នកជាប់ឃុំនៅព្រៃសត្រូវបង្ខំឱ្យធ្វើការយ៉ាងហោចណាស់ ៨ម៉ោង ក្នុងមួយថ្ងៃ និងធ្វើការពេលយប់ផងដែរ ពេលខែភ្លឺ ដែលការងារជាទូទៅធ្វើស្រែ ។ តាមសក្ខីកម្ម **ឌុច** ស្ត្រីសម្រាលកូនថ្មីៗក៏បង្ខំឱ្យធ្វើការដែរ ទោះបីជា មិនមានអ្នកមើលថែកូនរបស់ពួកគេក៏ដោយ ពួកគេត្រូវបង្ខំចិត្តយកកូនទៅស្រែជាមួយ ។

សំខាន់ជានេះទៀត **ឌុច** បានបញ្ជាក់ថា ពាក្យ *អប់រំកែប្រែ* គឺគ្រាន់តែជានាមប៉ុណ្ណោះ គ្មានអ្នកណាត្រូវបានដោះលែងពីមន្ទីរអប់រំកែប្រែព្រៃសទេ លើកលែងតែយុទ្ធជន ៣០នាក់ ដែលត្រូវបានបញ្ជូនទៅកងរថក្រោះនោះ ។ ព្រៃសខុសគ្នាពីមន្ទីរ ម-១៣ (ខ) ។

***ស្ថានភាពឃុំខ្លួន :*** ការដើរហើរ និងការនិយាយស្តី មិនត្រូវបានរឹតត្បឹតខ្លាំងដូចនៅមន្ទីរ ស-២១ ទេ អ្នកជាប់ឃុំអាចដើរហើរក្នុងបរិវេណមន្ទីរឃុំឃាំងបាន ចំណែកឯអ្នកយាមក៏ពុំកាន់អាវុធដែរ ។

ជំនួយផ្នែកពេទ្យស្ទើរតែគ្មាន បន្ទាប់ពីពេទ្យពីរនាក់ត្រូវបានសម្រិតសម្រាំង ។ **ឌុច** បានឱ្យដឹងថា ស្ត្រីមានផ្ទៃពោះសម្រាលកូននៅព្រៃស គឺគ្មានពេទ្យឆ្មបទេ ។

***ការសួរចម្លើយ និងការធ្វើទារុណកម្ម :*** **ឌុច** បានបដិសេធថា គ្មានការសួរចម្លើយ និងការធ្វើទារុណកម្មនៅមន្ទីរកែប្រែព្រៃសទេ ។ ប្រសិនបើមានក៏គាត់មិនបានដឹងដែរ ព្រោះគាត់មិនដែលចារលើចម្លើយសារភាពណាមួយចេញពីព្រៃសឡើយ ។

***ការសម្លាប់ :*** **ឌុច** អះអាងថា អ្នកជាប់ឃុំប្រហែល ៥៩០នាក់ បញ្ជូនពីព្រៃសទៅមន្ទីរ ស-២១ និងទៅកំទេចនៅវាលពិឃាដជើងឯក ។ ចំពោះក្មេងៗអាយុក្រោម ៧ឆ្នាំ ដែលមកជាមួយម្តាយ គឺត្រូវចាប់យកទៅជើងឯកភ្លាម ។

***ការចូលរួមរបស់ឌុច :*** **ឌុច** ជាប្រធានមន្ទីរ ស-២១ និងជាប្រធានមន្ទីរអប់រំកែប្រែព្រៃសផងដែរ ។ សមមិត្ត **ហ៊ុយ** ទទួលមើលការខុសត្រូវជាប្រចាំនៅព្រៃស និងរាយការណ៍ទៅឱ្យសមមិត្ត **ហូ** ហើយ **ហូ** រាយការណ៍បន្តទៅ **ឌុច** ។

**ឌុច** ទទួលស្គាល់ថា គាត់បានប្រគល់សិទ្ធិអំណាចឱ្យ **ហូ** និង **ហ៊ុយ** ដោយការជឿជាក់លើពួកគេ ។ គាត់អះអាង បន្ថែមថា ប្រសិនបើមានបញ្ហាមិនប្រក្រតីកើតឡើងនៅព្រៃស គាត់អាចបញ្ជាដោយផ្ទាល់ឱ្យបញ្ឈប់សកម្មភាពទាំងនោះ ដែលនេះផ្ទុយនឹងអ្វីដែលគាត់ធ្លាប់លើកឡើងថា គាត់គ្មានអំណាច ។ គាត់នៅតែអះអាងថា គាត់ធ្វើការងារគ្រប់បែបយ៉ាងដើម្បីធានាអាយុជីវិតខ្លួន ។

ម្យ៉ាងទៀត **ឌុច** នៅតែបដិសេធថា គាត់មិនមានសិទ្ធិផ្តល់អំណាចចាប់មនុស្សទេ គឺមានតែ **សុន សេន** ទទួលខុសត្រូវបញ្ជាចាប់ក្នុងជួរយោធា និងមេដឹកនាំកំពូល (**ប៉ុល ពត** និង **នួន ជា**) មានអំណាចក្នុងការចាប់ប្រជាជនខ្មែរទូទាំងផ្ទៃប្រទេស ។

**ឌុច** អះអាងថា បានទៅព្រៃស៤លើក ទី១ ទៅស្គាល់ទីតាំងភូមិសាស្ត្រ ទី២ ទៅបង្រៀនបុគ្គលិក ទី៣ ទៅជួបអ្នកទោសមកពីភូមិភាគបូព៌ា មុនដោះលែងឱ្យធ្វើជាកងរថក្រោះ និងទី៤ ទៅមើលគេចាប់ **ហ៊ុយ** ។ ទោះបីជាយ៉ាងណា **ឌុច** នៅតែអះអាងថា គាត់មិនដឹង និងអង្កេតមើលពីលក្ខខ័ណ្ឌនៃការឃុំខ្លួនអ្នកទោសនៅព្រៃសឡើយ ។

### គ. បញ្ហាលើកឡើងនៅពេលសវនាការ

បញ្ហាច្បាប់មិនត្រូវបានលើកឡើងទេនាសប្តាហ៍នេះ ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និងសាក្សី និងការការពារជនរងគ្រោះ និងការគាំទ្រ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមសវនាការ ៧រូប នៅថ្ងៃច័ន្ទ និង ៦រូបនៅថ្ងៃអង្គារ ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ដែលពួកគេមកពីក្រុម២ និងក្រុម៤ ទទួលការឧបថម្ភពីអង្គការអាដហុក ADHOC និង CHRAC ។

***ការកំណត់តួនាទីដើមបណ្តឹងរដ្ឋប្បវេណី :*** ការពិភាក្សាទាក់ទងនឹងតួនាទីដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានបំភ្លឺឡើយកាលពីថ្ងៃច័ន្ទ ។ មេធាវីការពារក្តីលោក **François Roux** បានជំទាស់ពីរបៀបតាំងសំណួរដោយមេធាវីដើមបណ្តឹងលោក **ហុង គីមសួន** ព្រោះកំពុងតាំងខ្លួនជា *"សហព្រះរាជអាជ្ញា"* ។ គាត់លើកហេតុផលថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានរឹតតួនាទី គឺត្រឹមតែការពារការឈឺចាប់ និងសំណងការខូចខាតរបស់កូនក្តីខ្លួន ហើយមេធាវីដើមបណ្តឹងគួរត្រូវអនុញ្ញាតឱ្យដេញដោលសំណួរពាក់ព័ន្ធផ្ទាល់ទៅជនរងគ្រោះ ។ តួនាទីជនរងគ្រោះនៅក្នុងនីតិវិធីព្រហ្មទណ្ឌ លោក **Roux** លើកឡើងថា គឺមិនដូចគ្នារវាងសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិជនជាប់ចោទ ។

ចំពោះការជំទាស់នេះ មេធាវីតំណាងដើមបណ្តឹងក្រុម១លោក **Alain Werner** បានលើកហេតុផលថា វិធាន២៣(១) នៃវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីក្នុងកិច្ចនីតិវិធី *"ជាអ្នកគាំទ្រសហព្រះរាជអាជ្ញា"* ។ គាត់បង្ហាញថា កាលពីកិច្ចប្រជុំរៀបចំសវនាការមុន បានរឹតសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីត្រឹមតែកុំឱ្យតាំងសំណួរច្រំដែល និងក្រៅប្រធានបទ ។ លោកមេធាវី **ហុង គីមសួន** បានគាំទ្របញ្ហានេះ ដោយលើកថា ភាគីដើមបណ្តឹង គឺជាជនរងគ្រោះទទួលរងការឈឺចាប់ និងការខូចខាតផលប្រយោជន៍ ដូច្នេះតំណាងដើមបណ្តឹងមានសិទ្ធិក្នុងការបង្ហាញឱ្យឃើញនូវផលប្រយោជន៍ដែលបានបំពាន ។

អង្គជំនុំជម្រះមិនបានបញ្ជាក់ពីតួនាទីច្បាស់លាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី យោងតាមវិធាន ២៣(១) បានអនុញ្ញាតដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោល *"ដើម្បីគាំទ្រសហព្រះរាជអាជ្ញា"* ។ អង្គជំនុំជម្រះនឹងបន្តការបកស្រាយច្បាប់ឱ្យទូលាយលើសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអនុញ្ញាតដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលលើបញ្ហាសំខាន់ៗពីការទទួលខុសត្រូវរបស់ជនជាប់ចោទលើបទចោទប្រកាន់ ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះនៅតែដាស់តឿនភាគីមិនឱ្យចោទសួរសំណួរច្រំដែល ការតាំងសំណួរវែង និងសំណួរក្រៅប្រធានបទ ។

***មេធាវីដើមបណ្តឹងចោទសួរក្នុងនាមជនរងគ្រោះ :*** នៅពេលជាមួយគ្នានេះ មេធាវីដើមបណ្តឹងបានកត់សម្គាល់លើតួនាទីខ្លួនក្នុងនាមជាជនរងគ្រោះពាក់ព័ន្ធនឹងកង្វល់ និងការចង់ដឹងចង់ឮរបស់ខ្លួន ។ ជាការពិត ការពិភាក្សាលើដែនកំណត់នៃតួនាទីកាត់ទោស គឺមេធាវីដើមបណ្តឹងពុំមានសិទ្ធិទេ ប៉ុន្តែដោយសារតែជនរងគ្រោះជាអ្នកទទួលរងព្យសនៈកម្ម ដូច្នេះទើបមានការច្នៃប្រឌិតឱ្យចូលរួមក្នុងនីតិវិធី ។ ***<u>ឧទា :</u>*** លោកមេធាវី **Alain Werner** បានឱ្យដឹងថា សំណួរមួយទៅកាន់ជនជាប់ចោទ គឺមិនជាក់លាក់ *"លើគ្រប់កូនក្តីដែលបានបាត់បង់ញាតិមិត្តខ្លួនទេ"* ។ ចំណែកមេធាវីដើមបណ្តឹងក្រុម៣ កញ្ញា **ម៉ុច សុវណ្ណារី** ក៏បានបញ្ជាក់ថា នាងក្នុងនាម

*"ចេតនារបស់ជនរងគ្រោះ"* សុំចោទសួរ **ឌុច** អំពីរយៈពេលជាក់លាក់នៃការឃុំខ្លួនអ្នកទោស **អ៊ុក កេត** ។ គំនិតផ្ដួចផ្ដើមដំបូងរបស់មេធាវីដើមបណ្ដឹងក្នុងការតំណាងឆន្ទៈ និងក្ដីកង្វល់កូនក្ដី គឺគួរឱ្យកោតសរសើរនាសប្ដាហ៍នេះ ។

***ភាពមិនអាចរកសម្លេងតែមួយបានរបស់ក្រុមមេធាវីដើមបណ្ដឹង :*** អង្គជំនុំជម្រះបានណែនាំដល់ភាគីដើមបណ្ដឹង ដោយសារតែរយៈពេល មានក៏រិតក្នុងការសួរដេញដោល មេធាវីទាំងបួនក្រុមគួរពិចារណារកសម្លេងរួមអាចជា មេធាវីជាតិ ១រូប និងអន្តរជាតិ ១រូប ប៉ុន្តែការណែនាំនេះពុំទទួលបានលទ្ធផលឡើយ ប្រហែលមិនមែនជាសេចក្ដីត្រូវការរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បើទោះមានរយៈពេលខ្លីក្នុងការសួរដេញដោល និងមិនបញ្ចប់នូវព័ត៌មានចង់បាន ។

***មេធាវីដើមបណ្ដឹងមិនមានសិទ្ធិសម្រេចដោយខ្លួនឯង :*** កាលពីថ្ងៃច័ន្ទ មេធាវីដើមបណ្ដឹងក្រុម២ លោកស្រី **Silke Studzinsky** ក្នុងនាមមេធាវីដើមបណ្ដឹងទាំងបួនក្រុមបានជូនដំណឹងអង្គជំនុំជម្រះថា ដើមបណ្ដឹងរដ្ឋប្បវេណីបានព្រមព្រៀងផ្លាស់ប្ដូរលំដាប់នៃការសួរដេញដោលខុសពីទំរង់ចាស់ ។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានជំទាស់នឹងការផ្លាស់ប្ដូរនេះ ដោយលើកឡើងថា មេធាវីដើមបណ្ដឹងមិនមានសិទ្ធិសម្រេចដោយឯកឯងនូវលំដាប់នៃការចោទសួរនោះទេ ។

***ការការពារសាក្សី :*** នៅថ្ងៃច័ន្ទ បន្ទាប់ពីការប្រកាសកាលវិភាគថ្មី ស្ដីពីបញ្ជីឈ្មោះសាក្សីក្នុងការផ្ដល់សក្ខីកម្ម អង្គជំនុំជម្រះបានការរំលឹកជាពិសេសដល់ភាគី គឺមិនត្រូវបញ្ចេញអត្តសញ្ញាណសាក្សីទេ ។ ភាគីមានការប្រុងប្រយ័ត្នក្នុងការអនុវត្តន៍សេចក្ដីសម្រេចនេះ ។

## ៤. ការគ្រប់គ្រងសវនាការ

***ការគ្រប់គ្រងផ្នែកតុលាការ :*** អង្គជំនុំជម្រះធ្វើការយ៉ាងសកម្មក្នុងការធានាឱ្យមានប្រសិទ្ធិភាពនៃកិច្ចនីតិវិធី ចំពោះការប្រឈមមុខនឹងការកំណត់កាលវិភាគ និងចៀសវាងសំណួរច្រំដែល ។ នៅថ្ងៃប្រហស្បត្តិ៍ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានឆ្លើយចម្លើយជំនួសជនជាប់ចោទនូវសំណួរច្រំដែលមួយរបស់មេធាវីដើមបណ្ដឹងក្រុម៤ លោក **ហុង គឹមសួន** ។

ទន្ទឹមនឹងការប្រកាន់ខ្ជាប់នូវការដឹកនាំនីតិវិធីឱ្យមានប្រសិទ្ធិភាព អង្គជំនុំជម្រះបានដាស់តឿនភាគីជាច្រើនលើកច្រើនសារកុំសួរសំណួរច្រំដែល ប៉ុន្តែនៅពេលលោកចៅក្រម **ធូមន្នី** សួរដេញដោល **ឌុច** ដែលជាសំណួរបានសួរហើយដោយប្រធានអង្គជំនុំជម្រះ ។ ករណីនេះ ប្រធានអង្គជំនុំជម្រះ **និល ណុន** មិនបានធ្វើអន្តរាគមន៍ដើម្បីបញ្ចៀសសំណួរទាំងនោះឡើយ ។

កំឡុងពេលសហព្រះរាជអាជ្ញាអន្តរជាតិលោក **William Smith** សួរដេញដោល អង្គជំនុំជម្រះបានបន្ថែមពេលដល់សហព្រះរាជអាជ្ញាចោទសួរជនជាប់ចោទ តើគាត់ពិតជាអនុវត្តការងារស្ថិតក្នុងភាពភ័យខ្លាច និងបង្ខិតបង្ខំ? តែសំណួរនេះហាក់ជាចូលក្នុងប្រធានបទថ្មី ស្ដីពីអត្តចរិកជនជាប់ចោទ ។

នៅថ្ងៃអង្គារ អង្គជំនុំជម្រះបានបដិសេធសំណើ **ឌុច** ក្នុងការថ្លែងទៅភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានវត្តមានក្នុងសាលសវនាការ ដោយផ្អែកលើមូលដ្ឋានថា ជនជាប់ចោទនឹងមានឱកាសធ្វើសេចក្ដីថ្លែងនៅចុងបញ្ចប់កិច្ចនីតិវិធី ។

នៅថ្ងៃពុធ ប្រហែលម៉ោង ៣រសៀល អង្គជំនុំជម្រះបានផ្អាកសវនាការមុនម៉ោងកំណត់ បន្ទាប់ពីអង្គជំនុំជម្រះបានបញ្ចប់ការដេញដោលរបស់ខ្លួនលើជនជាប់ចោទ ដោយសារតែ លោក **William Smith** សហព្រះរាជាអាជ្ញាភាគីអន្តរជាតិ និងមេធាវី

ដើមបណ្តឹងក្រុម១លោក **Alain Werner** បានសំណូមពរដល់អង្គជំនុំជម្រះពិចារណាឈប់សម្រាកមុនម៉ោងកំណត់ ដើម្បីរៀបចំសំណួរក្នុងការដេញដោលជនជាប់ចោទកុំឱ្យជាន់ជាមួយអង្គជំនុំជម្រះ ។ លោក **Smith** បានលើកឡើងថា រយៈពេលដេញដោលជនជាប់ចោទមានកំណត់ ដូច្នេះភាគីត្រូវរៀបចំសំណួរជាមុនដោយប្រុងប្រយ័ត្ន និងហ្មត់ចត់ ។

នៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះបានបញ្ឈប់សវនាការត្រឹមថ្ងៃត្រង់ កំឡុងពេលភាគីបានបញ្ចប់ការសួរដេញដោលជនជាប់ចោទលើអង្គហេតុមន្ទីរអប់រំកែប្រែព្រៃស ។

កាលពីថ្ងៃច័ន្ទ ***អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសវនាការ*** សម្រាប់សប្តាហ៍នេះ និងពីរសប្តាហ៍ទៅមុខទៀត ៖

| | |
|---|---|
| ២២/៦/០៩–២៤/៦/០៩ | ការសួរដេញដោលជនជាប់ចោទ ស្តីពីប្រតិបត្តិការនៅមន្ទីរ ស-២១ និង ជើងឯក ។ |
| ២៤/៦/០៩–២៥/៦/០៩ | ការសួរដេញដោលជនជាប់ចោទ ស្តីពីប្រតិបត្តិការនៅការិយាល័យសន្តិសុខមន្ទីរ ស-២៤ (ព្រៃស) |
| ៣០/៦/០៩–១៤/៧/០៩ | ការស្តាប់សក្ខីកម្មជនរងគ្រោះ ដែលនៅរស់មានជីវិតពីមន្ទីរ ស-២១ ដោយសាក្សីម្នាក់ផ្តល់សក្ខីកម្មក្នុង១ថ្ងៃ ហើយលំដាប់ ដូចជា KW-01, D25/3, D25/1, CP1/6, E2/61, E2/23, E2/33, E2/80, E2/32. |

***កិច្ចប្រជុំរៀបចំ ៖*** ជាដំបូង កិច្ចប្រជុំនេះគ្រោងធ្វើជាអសាធារណៈ នៅថ្ងៃព្រហស្បតិ៍ ទី២៥ ខែមិថុនា តែត្រូវលើកមកថ្ងៃអង្គារ ទី២៣ ខែមិថុនាវិញ ដោយសារមេធាវីការពារក្តីអន្តរជាតិ **Roux** មានបញ្ហាគ្រួសារជាបន្ទាន់ ។ អង្គជំនុំជម្រះក៏បានពិចារណាគួរកាត់បន្ថយសាក្សី ដើម្បីសន្សំពេលកិច្ចនីតិវិធីយ៉ាងតិច ៣០ថ្ងៃ ដែលសាក្សីដំបូង KW-01 នឹងមិនផ្តល់សក្ខីកម្មទេ ។

***ចម្លើយសារភាពបានមកពីទារុណកម្ម ៖*** កាលពីថ្ងៃអង្គារ នៅពេលមេធាវីដើមបណ្តឹងលោកស្រី **Studzinsky** ធ្វើការដេញដោល **ឌុច** លើចម្លើយសារភាពទាក់ទងនឹងឧក្រិដ្ឋកម្មផ្លូវភេទ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានក្រើនរំលឹកលោកស្រីមិនឱ្យប្រើប្រាស់ចម្លើយសារភាពបានមកពីទារុណកម្មទេ ។

***កង្វល់នៃការបកប្រែ*** ៖ នៅថ្ងៃអង្គារ គុណភាពនៃការបកប្រែនៅតែចោទឡើង ដែលរារាំងដល់ប្រសិទ្ធិភាពនៃកិច្ចនីតិវិធី ។ ក្រុមឃ្លាំមើលតុលាការរកឃើញថា ការបកប្រែពីភាសាខ្មែរទៅអង់គ្លេស ទាក់ទងនឹងសំណួររបស់សហមេធាវីការពារក្តីលោក **កា សាវុធ** ពិបាកយល់ ។ ភាគីគួរសហការធ្វើយ៉ាងណានិយាយយឺតៗ ដើម្បីងាយស្រួលដល់ការបកប្រែ ។

***វិន័យក្នុងសាលតុលាការ ៖*** នៅថ្ងៃច័ន្ទ លោកប្រធានអងជ្គំនុំជម្រះ **និល ណុន** មានលក្ខណៈតឹងរឹងខុសប្លែកពីធម្មតា ដោយបានក្រើនរំលឹកដល់លោកស្រីមេធាវី **Silke Studzinsky** ឱ្យគោរពតួនាទីអង្គជំនុំជម្រះ កុំកំណត់លំដាប់លេខរៀងនៃការសួរដេញដោលដោយខ្លួនឯង (សូមមើលផ្នែក *ការចូលរួមរបស់ជនរងគ្រោះ និងការការពារ និងការគាំទ្រសាក្សី*) ។ អង្គជំនុំជម្រះមានប្រតិកម្មខ្លាំងយ៉ាងនេះ ប្រហែលលោកស្រីមេធាវីធ្លាប់បានបំពាននីតិវិធីតុលាការណាមួយហើយ ។

***វត្តមានភាគី :*** គ្រប់ភាគីមានវត្តមាននាសប្តាហ៍នេះ លើកលែងតែមេធាវីការពារក្តីអន្តរជាតិលោក **François Roux** អវត្តមាន នៅថ្ងៃពុធ និងព្រហស្បត្តិ៍ ។

***វត្តមានសាធារណៈជន :*** នៅសាលសវនាការសាធារណៈមានអ្នកចូលច្រើនជាង ១០០នាក់ នៅថ្ងៃច័ន្ទ ប្រជាជន ៥៦នាក់ មកពីសង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ, ៤នាក់ មកពីខេត្តតាកែវ និង២៥នាក់ មកពីខេត្តព្រវែង ដែលឧបត្ថមដោយអង្គការ **MCC** ។ និស្សិតសកលវិទ្យាល័យ **Build Bright** និងនិស្សិតកម្មសិក្សាបរទេសមកពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក៏បានចូលរួមផងដែរ ។

នៅថ្ងៃអង្គារ ពុំមានវត្តមានអ្នកចូលរួមពីបណ្តាខេត្តទេ គឺមានតែបុគ្គលិកអង្គការ ស្ថានទូត និងនិស្សិតកម្មសិក្សាបរទេស ប្រហែលជា ៣០នាក់ ទៅ ៤០នាក់ ប៉ុណ្ណោះ ។

នៅថ្ងៃពុធ និងព្រហស្បត្តិ៍ វត្តមានអ្នកចូលរួមមានចំនួនច្រើន និស្សិតប្រហែល ១៥០នាក់ មកពី **Mekong Kampuchea University of Business** និងនៅថ្ងៃប្រហស្បត្តិ៍ មានប្រជាជនបន្ថែម ៥០នាក់ទៀត មកពីខេត្តកំពង់ឆ្នាំង សៀមរាប បាត់ដំបង និងកំពត ដែលឧបត្ថមដោយអង្គការ **Peace Youth Organization** ។

***បញ្ហាបច្ចេកទេស :*** ប្រធានអង្គជំនុំជម្រះ **និល ណុន** និងលោកស្រីចៅក្រម **Sylvia Cartwright** បានប៉ុងប៉ងបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រជាសាធារណៈ តែជួបប្រទះបញ្ហាបច្ចេកទេសរំខានប្រហែលពី ២-៣នាទី ។ សហព្រះរាជអាជ្ញាអន្តរជាតិបានឱ្យ ដឹងថា ក្រុមបច្ចេកទេសព័តិមានវិទ្យានឹងដោះស្រាយរួចរាល់នៅសប្តាហ៍ក្រោយ ។

## តារាងគ្រប់គ្រងពេលវេលា

| ថ្ងៃកាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាក់ព្រឹក | សម្រាកថ្ងៃត្រង់ | សម្រាក់រសៀល | បញ្ឈប់ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ចន្ទ័ ២២.០៦.០៩ | ០៩.០៥ | ១០.៤០-១១.០០ | ១២.១០-១៣.៣០ | ១៤.៥០-១៥.០៥ | ១៦.២៥ | ៥ម៉២៥នាទី |
| អង្គារ ២៣.០៦.០៩ | ០៩.០៥ | ១០.៣០-១០.៥០ | - | - | ១២.០០ | ២ ម៉ ៣៥ នាទី |
| ពុធ ២៤.០៦.០៩ | ០៩.០០ | ១០.២០-១០.៤៥ | ១២.១០-១៣.៣០ | - | ១៤.៤០ | ៣ ម៉ ៥៥នាទី |
| ព្រហស្បត្តិ៍២៥.០៦.០៩ | ០៩.០០ | ១០.៤០ – ១១.០ | - | - | ១២.០៥ | ២ ម៉ ៤៥នាទី |

**ចំនួនម៉ោងសរុបជាមធ្យម ៣ម៉ ៤០នាទី**

**ចំនួនម៉ោងសរុបសប្តាហ៍នេះ ១៤ម៉ ៤០នាទី**

**ចំនួនម៉ោងសរុប ថ្ងៃ សប្តាហ៍ សវនាការ ១៤០ម៉ ៣០នាទី ៣៣ថ្ងៃ ៩ សប្តាហ៍**

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (“កម្មវិធី”) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/_ ។